# មជ្ឈមណ្ឌល ភីឌីភី

PDP-CENTER

៣☆៧


# គោលនយោបាយហ៊ីវ/អេដស៍

## ប្រការ ១- សេចក្តីផ្តើម

ដោយសារតែបញ្ហា ហ៊ីវ/អេដស៍ជាបញ្ហាប្រឈមដ៏ធំសំរាប់ប្រទេសកម្ពុជា ហើយវាក៏ជាការប្រឈមរបស់ស្ថាប័ននានារួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ម្លោះហើយទើបមជ្ឈមណ្ឌលភីឌីភីសំរេចរៀបចំអោយមានគោលនយោបាយនេះឡើងក្នុងគោលបំណងដើម្បីបង្ការ ទប់ស្កាត់ការរីករាលដាល និង ការរើសអើងនានា នៅក្នុងចំណោមបុគ្គលិក និង សមាជិកសមាជិការបស់មជ្ឈមណ្ឌលភីឌីភី ព្រមទាំងក្រុមគោលដៅរបស់ខ្លួនផងដែរ ។

បច្ចុប្បន្ននេះទោះជាប្រេវ៉ាឡង់ហ៊ីវ/អេដស៍មានការធ្លាក់ចុះគួរអោយរីករាយបំផុតក្តី បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៧ ប្រេវ៉ាឡង់ អ្នកឆ្លងមេរោគហ៊ីវមាន៣,៣ ភាគរយ ហើយបានថយចុះជាបន្តបន្ទាប់រហូតដល់ ០,៩ ភាគរយនៅឆ្នាំ ២០០៦។[1] ប៉ុន្តែយុវជនកម្ពុជានៅតែ ប្រឈមមុខ នឹងគ្រោះថ្នាក់នេះនៅឡើយ។ ទោះបីអត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅ ក្នុងប្រទេសកម្ពុជា មានការធ្លាក់ចុះ ជាបន្តបន្ទាប់ក៏ដោយក៏មនុស្សពេញវ័យអាយុចន្លោះពី១៥-៤៩ឆ្នាំនៅក្នុងប្រទេស កម្ពុជាប្រហែល ៦៥,០០០នាក់កំពុងមានផ្ទុកមេរោគអេដស៍ ហើយអត្រាឆ្លងមេរោគហ៊ីវថ្មីនិងចំនួនអ្នកស្លាប់ ដោយជំងឺអេដស៍កំពុងតែកើតមានជាបន្តបន្ទាប់ ។[2]

គិតមកដល់ខែមិថុនាឆ្នាំ២០០៥រដ្ឋាភិបាលបានផ្តល់ថ្នាំពន្យាជីវិត ដល់អ្នកជំងឺចំនួន១១,០០០នាក់ហើយក្នុងនោះកុមារមានចំនួន១០០០នាក់ ។[3]

ដើម្បីចូលរួមចំណែកទប់ស្កាត់ និង បង្ការ ក៏ដូចជាការការ និង លើកទឹកចិត្តដល់អ្នកផុកមេរោគអេដស៍ មជ្ឈមណ្ឌលភីឌីភីសំរេចដាក់ចេញនូវគោលនយោបាយដូចខាងក្រោមៈ

## ប្រការ ២- វិសាលភាព

គោលនយោបាយនេះមានវិសាលភាពគ្រប់ដណ្តប់ទៅលើគ្រប់បុគ្គលិកទាំងអស់នៅមជ្ឈមណ្ឌលភីឌីភី ។

## ប្រការ៣- និយមន័យ

អេដស៍ គឺជាចង្កោមរោគសញ្ញាដែល កើតឡើងក្រោយភាពស៊ាំនៃប្រពន្ធ័រាង្គកាយយើងចុះខ្សោយ ។

### អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ៈ

#### ក- អ្នកផ្ទុកមេរោគអេដស៍ៈ

គឺជាអ្នកបានឆ្លងមេរោគនេះចូលទៅក្នុងខ្លួន តែវាមិនទាន់ចេញរោគសញ្ញាអ្វីទេ ហើយអ្នកផ្ទុកមេរោគ យើងមិនអាចមើល ដឹងបានដោយភ្នែកទទេតើអ្នកនោះផ្ទុកមេរោគ ឬមិនផ្ទុកមេរោគទេ។ ក្នុងរយៈពេលនេះវាអាចចំលងមេរោគទៅអ្នកដ៏ទៃបាន យ៉ាងងាយ ប្រសិនបើមានការរួមភេទដោយ មិនប្រើស្រោមអនាម័យ។ ពួកគេរស់នៅ

---

[1] *សេចក្តីប្រកាសពតិមានរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខភិបាលកម្ពុជា ថ្ងៃទី ២៨ មិថុនា ឆ្នាំ ២០០៨*

[2] Ibid

[3] STATEMENT TO THE 2006 CONSULTATIVE GROUP MEETING ON CAMBODIA NGO

ជាធម្មតាដូចមនុស្សទូទៅដែលគ្មានផ្ទុក មេរោគអាចធ្វើការជាមួយគ្នាដោយមិនឆ្លង។ មេរោគអេដស៍ ធ្វើអោយរាងកាយខ្លួនយើងចុះខ្សោយដោយ សារវា បានចូល ទៅបំផ្លាញសរីរាង្គម្យ៉ាងដែលទប់ទល់នឹងមេរោគ ឬជំងឺគ្រប់ប្រភេទ។

**ខ-អ្នកជំងឺអេដស៍:**

ពេលដំណាក់កាលចុងក្រោយមេរោគអេដស៍បានធ្វើសកម្មភាពចេញជា រោគសញ្ញាផ្សេងៗនៃជំងឺឱកាសនិយម ដូចជាក្អក រាំរ៉ៃ ដំបៅ ពងបែក ឡើងកូនកណ្ដុរ ផ្សិតនៅមាត់ បំពង់ក ជ្រាំងអណ្ដាត ទៅតាមជំងឺឱកាសនិយមរបស់អ្នកជំងឺម្នាក់ៗ រួចចុះទំងន់ ១០%នៃទំងន់ខ្លួនពីមុន។ ដំណាក់កាលនេះ អ្នកជំងឺរងចាំថ្ងៃស្លាប់នៅពេលដ៏ខ្លី។

**ប្រការ៤-ការប្រព្រឹត្តិទៅកាន់អ្នកផ្ទុកមេរោគហ៊ីវ ឬអ្នកជម្ងឺអេដស៍**

ក. បុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភីត្រូវប្រព្រឹត្តិចំពោះអ្នកផ្ទុកមេរោគហ៊ីវឬអ្នកជម្ងឺអេដស៍ដោយ គោរព និងគ្មានការរើសអើង។ មិនត្រូវប្រើកាយវិការ ពាក្យសម្ដី ឬ អាកប្បកិរិយាដោយប្រមាថ និង បង្ហាញចេញនូវការរើសអើងណាមួយចំពោះអ្នកផ្ទុក និង អ្នកជម្ងឺអេដស៍ជាដាច់ខាត។

ខ. ការប្រព្រឹត្តិដោយការគោរព និង គ្មានការរើសអើងនេះត្រូវធ្វើឡើងនៅគ្រប់កាលៈទេសៈ និង គ្រប់ទីកន្លែង។

គ. បុគ្គលិកមជ្ឈមណ្ឌលភីឌីភីត្រូវមានការប្រាស្រ័យទាក់ទងល្អជាមួយអ្នកផ្ទុក និង អ្នកជម្ងឺអេដស៍ ដោយបង្កើតអោយមានភាពស្និទ្ធស្នាល ស្របតាមប្រពៃណីល្អរបស់សង្គមខ្មែរយើង ។

ឃ. ការប្រព្រឹត្តិចំពោះអ្នកផ្ទុកហ៊ីវ និង អ្នកជម្ងឺអេដស៍ដូចបានរៀបរាប់ខាងលើនេះបុគ្គលិកត្រូវអនុវត្តផងដែរនៅតាមសហគមន៍ និងតំបន់គោលដៅនានារបស់មជ្ឈមណ្ឌលភីឌីភី។

**ប្រការ៥-ការលើកទឹកចិត្ត**

ក. ករណីមានបុគ្គលិកផ្ទុកមេរោគហ៊ីវ ឬជម្ងឺអេដស៍នៅក្នុងអង្គការត្រូវមានការលើកទឹកចិត្តដោយផ្ដល់នូវប្រាក់កំរៃសុខភាពបន្ថែម ៥ដុល្លាក្នុងមួយខែ។ ការផ្ដល់ជូននូវប្រាក់កំរៃសុខភាពបន្ថែមនេះអាចធ្វើទៅបាន លុះត្រាណាតែមានសំបុត្រធ្វើតេសឈាមពី មន្ទីរពេទ្យដែលមានការអនុញ្ញាតអោយធ្វើកិច្ចការនេះ។

ខ. មជ្ឈមណ្ឌលភីឌីភីផ្ដល់ពេលវេលាសំរាប់បុគ្គលិកផ្ទុកមេរោគហ៊ីវកដើម្បីទៅពិនិត្យសុខភាពតាមពេលវេលាដែលគ្រូពេទ្យបានកំណត់ ឬ តាមអាការៈប្រែប្រួលដែលត្រូវទៅកាន់មន្ទីរពេទ្យ។

គ. មជ្ឈមណ្ឌលភីឌីភី នឹងជ្រើសរើសជនបង្គោលពិសេសមួយដើម្បីផ្ដល់ពតិមាន និង ជួយផ្ដល់ប្រឹក្សា ដល់អ្នកផ្ទុក និង អ្នកជម្ងឺអេដស៍នៅក្នុងអង្គការ។

ឃ. ការជ្រើសរើសបុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភី នឹងមិនមានការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍។

ង. លើកទឹកចិត្តសហគមន៍អោយមានការរាប់អានរាក់ទាក់ចំពោះអ្នកផ្ទុក និង អ្នកជមឺអេដស៍នៅតាមសហគមន៍។

ច. ករណីដែលស្ថានភាពជម្ងឺធ្ងន់ធ្ងរមិនអាចធ្វើការបាន ដែលគ្រូពេទ្យសណ្ណែនថា អ្នកជម្ងឺស្ថិតក្នុងដំណាក់កាលចុងក្រោយ នោះមជ្ឈមណ្ឌលភីឌីភី នឹងផ្ដល់ជូនប្រាក់ខែអាស្រ័យលើចំនួនឆ្នាំ ដែលបានធ្វើការ ចាប់ពីមួយខែ ដល់ បីខែនៃទឹកប្រាក់ខែចុងក្រោយរបស់ខ្លួនស្របតាមគោលនយោបាយបុគ្គលិក។

ឆ. ចំពោះបុគ្គលិកដែលមិនទាន់បានបញ្ចប់រយៈពេលសាកល្បងការងារចំនួនបីខែ ហើយស្ថានភាពជម្ងឺបានធ្លាក់ចូលទៅក្នុងដំណាក់កាលចុងក្រោយ នោះនឹងផ្តល់ជូនចំនួនកន្លះខែនៃទឹកប្រាក់ខែចុងក្រោយរបស់ខ្លួន ។

**ប្រការ ៦-ការការពារការឆ្លង**

ក. អញ្ជើញអ្នកជំនាញការផ្នែកហ៊ីវ/អេដស៏អោយធ្វើការផ្សព្វផ្សាយអោយមានការយល់ដឹងជាទូទៅពីគ្រោះថ្នាក់នៃមេរោគហ៊ីវ/អេដស៏នៅក្នុងចំណោមបុគ្គលិករបស់មជ្ឍមណ្ឌលភីឌីភី ។

ខ.ជនបង្គោលនឹងធ្វើការផ្តល់ពតិមានជាប្រចាំដល់បុគ្គលិកមជ្ឍមណ្ឌលភីឌីភី ដើម្បីអោយបានជ្រួតជ្រាបបន្ថែម ។

គ. បញ្ច្រាបហ៊ីវ/អេដស៍នៅក្នុងកម្មវិធីរបស់មជ្ឍមណ្ឌលភីធីភីដើម្បីអោយប្រជាពលរដ្ឋមានការយល់យល់ដឹង និងកាត់បន្ថយនូវការរើសអើងចំពោះអ្នកផ្ទុក និង អ្នកជម្ងឺអេដស៏ ។

**ប្រការ៧- វិធានការណ៍**

ក. ចំពោះបុគ្គលិកដែលមានការរើសអើងឬ ប្រមាថចំពោះអ្នកផ្ទុក និង អ្នកជម្ងឺអេដស៏ត្រូវព្រមានតាមមាត្រា២0 នៃលក្ខន្តិកៈរបស់មជ្ឍមណ្ឌលភីឌីភី ។

ខ. អ្នកផ្ទុកមេរោគហ៊ីវ និងអ្នកជមឺអេដស៏ ដែលមានចេតនាបង្កការចំលងទៅដល់អ្នកដទៃ នឹងប្តឹងទៅតុលាការដើម្បីផ្តន្ទាទោស តាមច្បាប់ ។

គ. រដ្ឋបាលនៃមជ្ឍមណ្ឌលភីឌីភីត្រូវធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់បុគ្គលិកទាំងនៅរាជធានី និងតាមបណ្តាខេត្តនានា ។

ឃ. រដ្ឋបាលត្រូវជ្រើសរើសជនបង្គោលអោយបានយ៉ាងយូរមួយខែបន្ទាប់ពីគោល នយោបាយនេះបានចូលជាធរមាន ។

ង. ជនបង្គោលត្រូវធ្វើផែនការស្តីពីការផ្សព្វផ្សាយ ដោយអញ្ជើញអ្នកជំនាញការមកចែកចាយចំណេះដឹង និងបទពិសោធន៏ ។

**ប្រការ៨ -អន្តរប្បញ្ញត្តិ**

ក. គោលនយោបាយនេះក្រោយពីបានធ្វើការអនុម័ត ត្រូវប្រកាសអោយចូលជាធរមានភ្លាមដោយប្រធានគណកម្មាធិការគ្រប់គ្រង ។

ខ. គោលនយោបាយនេះអាចកែលំអ ឬសើរើបានក្នុងករណីមានសំណើសុំពីគណកម្មាធិការគ្រប់គ្រង ឬ ពីក្រុមប្រឹក្សាភិបាល នៃ មជ្ឍមណ្ឌលភីឌីភី ដោយសំលេង៥0 ភាគរយ បូក ១ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១១

**មជ្ឈមណ្ឌលភីឌីភី**

**ប្រធាន**

**យ៉ង់ គិមអេង**

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១១

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**វង្ស ស្រីនួច**